# ប៊េកឃើរ ធីលលី ត្រូវបានទទួលស្គាល់ដោយ HR Asia ថា ជាក្រុមហ៊ុនដែលដ៏ល្អបំផុត សម្រាប់ធ្វើការងារនៅក្នុងតំបន់អាស៊ី

2021-01-04 04:47pm

**(ភ្នំពេញ)៖** ក្រុមហ៊ុនប៊េកឃើរ ធីលលី (ខេមបូឌា) ឯក (Baker Tilly Cambodia Co., Ltd) (BTC) ជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដទៃទៀតជាច្រើន ដែលមានវត្តមានក្នុងប្រទេសកម្ពុជា ដែលត្រូវបានទទួលស្គាល់ដោយ HR Asia ថា ជាក្រុមហ៊ុនដែលដ៏ល្អបំផុតសម្រាប់ធ្វើការងារនៅក្នុងតំបន់អាស៊ី។

BTC គឺជាបុត្រសម្ព័ន្ធនៃ Baker Tilly ដែលជាក្រុមហ៊ុនដ៏ធំផ្នែកគណនី និងប្រឹក្សាដ៏ធំលំដាប់ទី ១០ ក្នុងពិភពលោក។ BTC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៧ ហើយបច្ចុប្បន្ន BTC កំពុងបោះជំហ៊ានក្លាយជាក្រុមហ៊ុនដែលឈានមុខគេក្នុងប្រទេសក្នុងការផ្តល់សេវាកម្មគណនី និងប្រឹក្សា។

ក្រុមហ៊ុន BTC ផ្តល់ជូននូវសេវាកម្មដែលប្រកបដោយវិជ្ជាជីវៈជាច្រើនដែលរួមមាន សេវាកម្មផ្នែកសវនកម្ម សេវាកម្មផ្នែកសារពើពន្ធ សេវាកម្មផ្នែកគណនី សេវាកម្មផ្នែកចុះបញ្ជីក្រុមហ៊ុន សេវាកម្មផ្នែកស៊ើបអង្កេតខាងកោសល្យវិច្ច័យទៅលើគណនី សេវាកម្មផ្នែកស្តារនិងរៀបចំរចនាសម្ព័ន្ធឡើងវិញ និងការគ្រប់គ្រងការក្ស័យធន។

ក្រុមហ៊ុននេះមិនត្រឹមតែចូលរួមផ្នែកអភិវឌ្ឍផ្នែកពាណិជ្ជកម្មប៉ុន្នោះទេ តែថែមទាំងបានចូលរួមយ៉ាងសកម្មក្នុងផ្នែកសប្បុរសធម៌ផងដែរ។ ថ្មីៗនេះក្រុមហ៊ុន BTC បានបរិច្ចាគនូវកំព្យូទ័រយួរដៃចំនួន ៦ គ្រឿងជូន ក្រុមជំនុំល្អភ្នំពេញកម្ពុជា (Full Gospel Assembly Cambodia Child Care Centre) ដើម្បីជួយដល់ការសិក្សាតាមប្រព័ន្ធអនឡាញរបស់សិស្សានុសិស្សដែលមានវត្តមាននៅទីនោះ។

ក្នុងឆ្នាំ ២០២០ BTC គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំង ១៩ ក្នុងព្រះរាជាណាចក្រកម្ពុជាទដែលបានទទួលនូវការទទួលស្គាល់ដ៏មានកិត្យានុភាពនេះ។ ជារៀងរាល់ឆ្នាំ HR Asia ទទួលស្គាល់ក្រុមហ៊ុនកំពូលៗមកពី ១២ ប្រទេសនៅអាស៊ី រួមទាំងប្រទេសកម្ពុជាផងដែរ។ ស្ថាប័ន Business Media International បានបោះផ្សាយថា HR Asia គឺស្ថាប័នដ៏ធំក្នុងចំណោមស្ថាប័នដទៃទៀតដែលផ្សព្វផ្សាយ និងមានសិទ្ធអំណាចក្នុងការប្រកាសជាសាធារណ: (the largestcirculating and most authoritativepublications) សម្រាប់វិស័យធនធានមនុស្សដែលប្រកបដោយវិជ្ជាជីវៈនៅក្នុងពិភពលោក

ដោយការវាយតម្លៃ គឺផ្អែកទៅលើគំរូវាយតម្លៃការចូលរួមសរុប ឬក៏ហៅកាត់ថា TEAM (Total Engagement Assessment Model or TEAM)។

និយោជិកត្រូវបានសួរអំពីការវាស់ស្ទង់លើក្រុមហ៊ុននីមួយៗ ដោយផ្អែកទៅលើ វប្បធម៌សាជីវកម្ម ការផ្តួចផ្តើមគំនិត ភាពជាអ្នកដឹកនាំ និងកត្តាផ្សេងៗទៀតជាច្រើនទៀត។ BTC គឺពិតជាសាកសមបំផុតដើម្បីឈ្នះនូវពានរង្វាន់ដ៏មានកិត្យានុភាពនេះពិតមែន ដោយហេតុថាក្រុមហ៊ុន Baker Tilly យកតម្លៃបុគ្គលិកជាធំ។

លោក KM TAN ដែលជា Managing Partner នៃក្រុមហ៊ុន BTC បានប្រាប់ឲ្យដឹងថា **«យើងតែងតែជឿដូច្នេះថា ប្រសិនបើយើងយកចិត្តទុកដាក់ទៅលើបុគ្គលិករបស់យើង នោះបុគ្គលិករបស់យើង និងយកចិត្តទុកដាក់ទៅលើមុខជំនួញរបស់យើងដូចគ្នា»**។

ក្រុមហ៊ុន BTC តែងតែយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍធនធានមនុស្ស បរិយាកាសការងារប្រកបដោយផាសុខភាព តុល្យភាពជីវិត និងកត្តាផ្សេងៗទៀត។ ក្នុងនោះ BTC បានរៀបចំការបណ្តុះបណ្តាលយ៉ាងទៀងទាត់ ដើម្បីធានាថាបុគ្គលិករបស់ក្រុមហ៊ុននឹងទទួលបាននៅចំនេះដឹងថ្មីៗ ដែលពួកគេអាចយកមកអនុវត្តក្នុងការងារ។

នៅក្នុងក្រុមហ៊ុន BTC ក៏មានអ្នកណែនាំសម្រាប់បុគ្គលិកថ្មីផងដែរ។ ក្រុមហ៊ុនតែងតែសង្កត់ធ្ងន់ថាបុគ្គលិកថ្មីរបស់ក្រុមហ៊ុនទទួលបានការណែនាំគ្រប់គ្រាន់ ជាមួយនឹងបរិយាកាសការងារថ្មីសម្រាប់ពួកគេក្នុងការសម្របខ្លួនជាមួយ និងវប្បធម៌របស់ក្រុមហ៊ុន។ ក្រុមហ៊ុនក៏មានកម្មវិធីឧបត្ថម្ភជំនាញផ្នែកវិជ្ជាជីវៈចំនួនពីរផងដែរ (សមាគមគណនេយ្យករដែលមានសញ្ញាប័ត្រវិញ្ញាបនប័ត្រ ឬ ACCA និងអ្នកបច្ចេកទេសគណនេយ្យដែលមានវិញ្ញាបនបត្រ ឬ CAT)។

ក្រុមហ៊ុន BTC ត្រូវបានគេទទួលស្គាល់ថាជានិយោជិកដែលបានអនុម័ត (Platinum) នៅក្នុងប្រទេសកម្ពុជាដោយ ACCA ។ និយោជិកដែលបានអនុម័តដោយ ACCA គឺជាការទទួលស្គាល់ដ៏មានកិត្តិយសដែលបច្ចុប្បន្ននេះមានតែក្រុមហ៊ុនចំនួន ១៧ ប៉ុណ្ណោះដែលទទួលស្គាល់ពី ACCA នៅក្នុងប្រទេសកម្ពុជា។ ដើម្បីជំរុញភាពសហការគ្នា ក្រុមហ៊ុនបានរៀបចំកម្មវិធីសង្គមជាប្រចាំដូចជាការប្រារព្ធខួបកំណើតរបស់បុគ្គលិកប្រចាំខែ។ នៅក្នុង ក្រុមហ៊ុន BTC តុល្យភាពជីវិត និងការងារត្រូវបានលើកទឹកចិត្ត។

ក្រុមហ៊ុនក៏បង្កើតដំណើរកម្សាន្តប្រចាំឆ្នាំសម្រាប់គណៈគ្រប់គ្រង និងបុគ្គលិក។ ដំណើរកម្សាន្តនេះតែងតែភ្ជាប់ជាមួយ នឹងសកម្មភាពសហការជាក្រុមក្នុងគោលដៅដើម្បីបង្កើតទំនុកចិត្ត និងជំរុញសាមគ្គីភាពនៅក្នុងរង្វង់ក្រុមគ្រប់ដណ្តប់គ្រប់ផ្នែកទាំងអស់នៅក្នុងក្រុមហ៊ុន។ ក្រុមហ៊ុនក៏បានបង្កើតកម្មវិធីបញ្ជូន

បុគ្គលិកទៅក្រៅប្រទេស ដែលបុគ្គលិកក្នុងស្រុកត្រូវបានបញ្ជូនទៅកាន់បណ្តាញក្រុមហ៊ុនដទៃផ្សេងទៀតរបស់ (Baker Tilly) នៅក្រៅប្រទេសកម្ពុជាសម្រាប់រយៈពេល ៦ ខែ។

ក្រុមហ៊ុនបានចង្អុលបង្ហាញថា «**នេះគឺជាឱកាសមាសរបស់បុគ្គលិកជនជាតិខ្មែរក្នុងការរៀន និងធ្វើការជាមួយជាតិសាសន៍ផ្សេងៗទៀត និងចូលរួមកិច្ចការសវនកម្មដែលយើងមិនដែលមានឱកាសជួបប្រទះក្នុងប្រទេសកម្ពុជា**»។

អំឡុងពេលនៃការឆ្លងរាលដាលនៃវីរុសកូរ៉ូណានេះ ក្រុមហ៊ុន BTC បានផ្តល់អាទិភាពទៅលើប្រាក់ខែ និងសុខុមាលភាពជូនទៅដល់បុគ្គលិកទាំងអស់ ដោយបានផ្តល់ជូននូវការតំឡើងប្រាក់ខែ បើកប្រាក់រង្វាន់ និងប្រាក់អតីតភាពការងារដូចធម្មតាក្នុងឆ្នាំ ២០២០ នេះទោះបីជារដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការពន្យារពេល ដោយសារជំងឺរាតត្បាតនេះក៏ដោយ។ បន្ថែមពីនេះ ក្រុមហ៊ុន BTC បានផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ផ្ទាល់ខ្លួនដល់បុគ្គលិកទាំងអស់ និងមានអាហារថ្ងៃត្រង់ផ្តល់ជូនបុគ្គលិកទាំងអស់គ្នានៅក្នុងការិយាល័យផងដែរ។

សរុបសេចក្តីមក ក្រុមហ៊ុន BTC គឺជានិយោជិកល្អបំផុតក្នុងប្រទេសកម្ពុជា ព្រោះថាតែក្រុមហ៊ុនមួយចំនួនតូចប៉ុណ្ណោះនៅប្រទេសកម្ពុជា ដែលមានភាពលេចធ្លោរជាងអ្វីដែលក្រុមហ៊ុន BTC កំពុងតែធ្វើ ឬបានធ្វើសម្រាប់បុគ្គលិករបស់ខ្លួន៕



FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង

bakertilly




ក្រុមហ៊ុនប៊ើកឃើរ ធីលលី(ខេមបូឌា)ឯក បានទទួលពានរង្វាន់នយោជិកឆ្នើមពី HR-អាស៊ី។



ក្រុមហ៊ុនបេកឃើរ ធីលលី(ខេមបូឌា)ឯក មានការរៀបចំដំណើរកម្សាន្តប្រចាំឆ្នាំ២០១៩ ទៅកាន់កោះឋានសួគ៌។



ក្រុមហ៊ុនប៊េកឃើរ ធីលលី(ខេមបូឌា)ឯក មានការរៀបចំដំណើរកម្សាន្តប្រចាំឆ្នាំ ២០២០ ទៅកាន់ខេត្តសៀមរាប។

FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង

bakertilly



ក្រុមហ៊ុនបេ៊កឃើរ ធីលលី(ខេមបូឌា)ឯក បានបរិច្ចាគកំព្យូទ័រចំនួន ៦ គ្រឿង ដល់ Gospel Assembly Cambodia Child Care Centre ដើម្បីជួលសម្រួលដល់ការសិក្សាររបស់សិស្សានុសិស្ស តាមប្រព័ន្ធអនឡាញ។



ក្រុមហ៊ុនបេក ឃើរ ធីលលី(ខេមបូឌា)ឯក មានកម្មវិធីបញ្ជូនបុគ្គលិកទៅកាន់បណ្តាញក្រុមហ៊ុនបេក ឃើរ ធីលធីនៅប្រទេសម៉ាឡេស៊ី។

Source: https://plus.freshnewsasia.com/index.php/en/freshnewsplus/182662-2021-01-04-09-47-01.html